សុន្ទរកថារបស់ **លោក ហ៊ីរ៉ូឌី យ៉ូស៊ីហ៊ីរ៉ូ**

ឧបទូត/អនុប្រធានបេសកកម្មទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធនៅអនុវិទ្យាល័យគោកបញ្ជាន់ រាជធានីភ្នំពេញ

២០ កញ្ញា ២០១៣

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**
**សូមគោរព ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីចូលរួមក្នុងពិធីសម្ពោធនៅអនុវិទ្យាល័យគោកបញ្ជាន់នៅថ្ងៃនេះ ជាមួយនឹងវត្តមានរបស់ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមអភិបាលរាជធានី និង បុគ្គលិករបស់ឯកឧត្តមដែលបានរៀបចំឲ្យមានពិធីនេះឡើង។

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលពិធីសម្ពោធនេះត្រូវបានធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣នេះដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះបន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសឡើងវិញរហូតបានក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើនក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះផងដែរ វិស័យអប់រំបានបន្តរីកចំរើនទាំងបរិមាណ និង គុណភាពពីមួយឆ្នាំទៅមួយឆ្នាំ។

ខ្ញុំសូមធ្វើការកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល កម្ពុជា ក្នុងការកែលម្អវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់ នៃការអប់រំថាជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាល ជប៉ុន បាននិងកំពុងបន្តផ្តល់ជំនួយ ឧបត្ថម្ភរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា តាមរយៈការជួយ សាងសង់ សាលារៀន ក៏ ដូចជាបណ្តុះបណ្តាលគ្រូបង្រៀន ជាដើម។

ទោះជាយ៉ាងណាក៏ដោយ នៅមានបញ្ហាប្រឈមជាច្រើនសម្រាប់ការកែលម្អបន្ថែមក្នុងវិស័យអប់រំ។ ហើយ បញ្ហាចាំបាច់មួយក្នុងចំណោមបញ្ហាដែលត្រូវកែលម្អនោះគឺអត្រាចូលរៀននៅកម្រិតអនុវិទ្យាល័យដែលនៅមិនទាន់ឈានដល់កម្រិតដែលអាចទទួលយកបាន ដោយសារតែកង្វះសាលារៀន។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សនៃអនុវិទ្យាល័យគោកបញ្ញាន់ត្រូវប្រើប្រាស់បន្ទប់សិក្សារបស់សាលាបឋមសិក្សាដែលនៅក្បែរនេះដោយពួកគេគ្មានបន្ទប់រៀនផ្ទាល់ខ្លួន។ ឥឡូវនេះ អគារសិក្សាថ្មីដែលមាន៧បន្ទប់ និងបន្ទប់អនាម័យ បានសាងសង់រួចរាល់ហើយ ហើយសិស្សានុសិស្សទាំងអស់ក៏អាចសិក្សានៅក្នុងអគារសិក្សាផ្ទាល់របស់ពួកគេបានដែរ។

ខ្ញុំសង្ឃឹមថាសិស្សានុសិស្សនៃអនុវិទ្យាល័យ គោកបញ្ញាន់ ទាំងអស់នឹងខិតខំប្រឹងប្រែងរៀនសូត្រនៅក្នុងបន្ទប់សិក្សាថ្មីដែលមានបរិស្ថានសិក្សាល្អប្រសើរនេះ ហើយនឹងជួយថែរក្សាអគារនេះឲ្យបានគង់វង្សល្អទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យ គម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!